ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៦ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣

# លិខិតប្រគល់សិទ្ធិ

យោងប្រកាសលេខ ៩៤០ សហវ. ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រកាសលេខ ៩៤១ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំសូមប្រគល់សិទ្ធិជូនថ្នាក់ដឹកនាំក្រសួងដូចតទៅ ÷

១- ឯកឧត្តមរដ្ឋលេខាធិការ មានសិទ្ធិពិនិត្យ ផ្តល់គោលការណ៍ និង ចុះហត្ថលេខា លើអាណត្តិបើកប្រាក់ទូទាត់បុរេប្រទាន រជ្ជទេយ្យបុរេប្រទាន ក្នុងក្របខ័ណ្ឌ ក្រសួង ស្ថាប័ន ឬ អង្គភាពដែលបានប្រគល់ជូនតាមរយៈប្រកាសយោងខាងលើ ក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជំពូក ៦០ ជំពូក ៦១ (ដោយមិនរាប់បញ្ចូលអនុគណនី ៦១៥៣) និង ជំពូក ៦២ ។ ដោយឡែក សម្រាប់ជំពូក ៦០ ជំពូក ៦១ (ដោយមិនរាប់បញ្ចូលអនុគណនី ៦១៥៣) និង ជំពូក ៦២ ចាប់ពីទឹកប្រាក់ ៥០០ លានរៀលឡើង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកចុះហត្ថលេខា បន្ទាប់ពីបានទទួលមតិពីឯកឧត្តមរដ្ឋលេខាធិការ លើកលែងតែអាណត្តិបើកប្រាក់ទូទាត់បុរេប្រទាន និង រជ្ជទេយ្យបុរេប្រទាន ឯកឧត្តមរដ្ឋលេខាធិការ មានសិទ្ធិចុះហត្ថលេខាក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមិនកំណត់ចំនួនទឹកប្រាក់ ។

២- ឯកឧត្តមអនុរដ្ឋលេខាធិការ មានសិទ្ធិពិនិត្យ ផ្តល់គោលការណ៍ និង ចុះហត្ថលេខា លើអាណត្តិបើកប្រាក់ទូទាត់បុរេប្រទាន រជ្ជទេយ្យបុរេប្រទាន ក្នុងក្របខ័ណ្ឌ ក្រសួង ស្ថាប័ន ឬ អង្គភាពដែលបានប្រគល់ជូន តាមរយៈប្រកាសយោងខាងលើ ក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជំពូក ៦០ ជំពូក ៦១ (ដោយមិនរាប់បញ្ចូលអនុគណនី ៦១៥៣) និង ជំពូក ៦២ ។ ដោយឡែកសម្រាប់ជំពូក ៦០ ជំពូក ៦១ (ដោយមិនរាប់បញ្ចូលអនុគណនី ៦១៥៣) និង ជំពូក ៦២ ចាប់ពីទឹកប្រាក់ ៥០០ លានរៀលឡើង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកចុះហត្ថលេខា បន្ទាប់ពីបានទទួលមតិពីឯកឧត្តមអនុរដ្ឋលេខាធិការ និង រដ្ឋលេខាធិការទទួលបន្ទុកវិស័យ ។

៣- ការប្រគល់សិទ្ធិតាមចំណុច ១ និង ២ ខាងលើនេះ មិនគ្របដណ្តប់ទៅលើ ÷

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-[illegible]
Phone : 855-23-724 664 Fax : 855-23-427 798

ទី១- ការចុះហត្ថលេខាលើលិខិតបុរេប្រទានថវិកា ។

ទី២- រាល់ការសំរេច ឬបញ្ជាទៅអគ្គនាយកដ្ឋានរតនាគារជាតិដែលពាក់ព័ន្ធនឹងការបង្វែរ ផ្ទេរ និងដកសាច់ប្រាក់ ។

ទី៣- រាល់ការសំរេច ឬបញ្ជាទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានពន្ធដារ ដែលពាក់ព័ន្ធទៅនឹងការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យរួចពន្ធ ការលើកលែងពន្ធ និងឱ្យបន្ធូរបន្ថយពន្ធ ។

ទី៤- ការចុះហត្ថលេខាលើសារាចរណែនាំ សេចក្តីសំរេច និងប្រកាស ។

កិច្ចការទាំង៤ខាងលើ ក្នុងចំណុច៣នេះ មានវេទយិតភាពខ្ពស់ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកសំរេច និង ចុះហត្ថលេខា ។ ចំពោះរាល់ចំណារសំរេច ឬបញ្ជារបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និង អគ្គនាយកដ្ឋានពន្ធដារ ត្រូវមានប្រថាប់ត្រាលើចំណារ ឬបញ្ជាទាំងនោះ ទើបចាត់ទុកជាផ្លូវការបាន ។

៤- ចំពោះការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ ដូចមានចែងក្នុងប្រកាសលេខ៩៥០សហវ. ប្រក ចុះថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ប្រកាសលេខ ៩៥២សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរក្សាសុពលភាពជាធរមានដដែល ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ត អូន ព័ន្ធមុនីរ័ត្ន

**<u>ចម្លងជូន</u>:**

- គ្រប់ថ្នាក់ដឹកនាំ នៃ កសហវ.
- គ្រប់អគ្គនាយកដ្ឋាន និងគ្រប់នាយកដ្ឋាន នៃ កសហវ.
- ឯកសារ- កាលប្បវត្តិ